ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ផែនការគ្រប់គ្រង
កន្លែងសហគមន៍នេសាទកំពង់សាមគ្គី
រយៈពេល ៣ឆ្នាំ (មីនា ២០២៦ - ធ្នូ ២០២៨)

ឈ្មោះសហគមន៍នេសាទ ៖ កំពង់សាមគ្គី
ភូមិ ៖ កំពង់ត្នោត
ឃុំ ៖ កូនសត្វ
ស្រុក ៖ ទឹកឈូ
ខេត្ត ៖ កំពត

រៀបចំដោយរដ្ឋបាលជលផលសហការជាមួយនឹងរដ្ឋបាលជលផលកំពត (គម្រោងជលផលសមុទ្រនិងតំបន់ឆ្នេរប្រកបដោយចីរភាព)

មាតិកា
ផែនការគ្រប់គ្រងកន្លែងសហគមន៍ឆេសាទ

១- ស្ថានភាពទូទៅ.....១
២- អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម.....២
ក- ប្រជាពលរដ្ឋ.....២
ខ- មុខរបរ.....៣
៣- កន្លែងឆេសាទសហគមន៍ និងធនធានដែលមានទៅក្នុងកន្លែងឆេសាទសហគមន៍.....៣
ក- ទីតាំង.....៣
ខ- ដែនឆេសាទ.....៣
គ- តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស.....៣
ឃ- ធនធានជលផល.....៤
៤- ការធ្វើឆេសាទ.....៤
ក- អ្នកឆេសាទ.....៤
ខ- ឧបករណ៍ឆេសាទ.....៤
គ- ការប៉ាន់ប្រមាណជលចាប់ប្រចាំឆ្នាំ.....៦
៥- ផែនការគ្រប់គ្រងសហគមន៍ឆេសាទ.....៧
ក- ទស្សនៈវិស័យ.....៧
ខ- គោលបំណង.....៧
គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍.....៧
ផ្នែកទី១.ការអភិបាលរកិច្ចនិងការគ្រប់គ្រង.....៧
គ១- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ.....៧
គ២- ផែនការប្រជុំប្រចាំខែនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ.....៨
គ៣- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល.....៨
គ៤- ផែនការប្រើប្រាស់ឧបករណ៍នេសាទ.....៩
គ៥- ផែនការទប់ស្កាត់បទល្មើសជលផល.....១០
គ៦- ផែនការកែលម្អកន្លែងនេសាទសហគមន៍.....១១
គ៧- ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ.....១២
គ៨- ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្តាមសេះរបស់សហគមន៍នេសាទ.....១២
គ៩- ផែនការគ្រប់គ្រងព្រៃកោកាង.....១៣
ផ្នែកទី២. សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នេសាទ.....១៤
គ១០- ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍នេសាទ.....១៤
គ១១- ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ.....១៥
គ១២- ផែនការបង្កើតកន្លែងទេសចរណ៍ធម្មជាតិរបស់សហគមន៍នេសាទ.....១៦
គ១៣- ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ.....១៧
ផ្នែកទី៣. **ការចូលរួមរបស់ស្ត្រីនិងយុវជន ការកសាងភាពធននឹងការប្រែប្រួលអាកាសធាតុ**.....១៨
គ១៤- ផែនការផ្សព្វផ្សាយនិងជ្រើសរើសស្ត្រីនិងយុវជនចូលជាសមាជិកសហគមន៍នេសាទ.....១៨
គ១៥- ផែនការកសាងភាពធននឹងការប្រែប្រួលអាកាសធាតុ.....១៨

ផ្នែកទី៤. ការទំនាក់ទំនងនិងគៀងគរធនធាន.....១៩
គ១៦-ផែនការទំនាក់ទំនងនិងគៀងគរធនធាន.....១៩
គ១៧- ផែនការចរិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍.....២០
ឃ- ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ.....២០
ង. ផែនការយុទ្ធសាស្ត្រ.....២១
តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ រយៈពេល៣ឆ្នាំ.....២២
តារាងពេលវេលាការងារ.....២៩

មាតិកា
ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

១- ស្ថានភាពទូទៅ.....១
២- អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម.....២
ក- ប្រជាពលរដ្ឋ.....២
ខ- មុខរបរ.....៣
៣- កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងកន្លែងនេសាទសហគមន៍.....៣
ក- ទីតាំង.....៣
ខ- ដែននេសាទ.....៣
គ- តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស.....៣
ឃ- ធនធានជលផល.....៤
៤- ការធ្វើនេសាទ.....៤
ក- អ្នកនេសាទ.....៤
ខ- ឧបករណ៍នេសាទ.....៤
គ- ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ.....៦
៥- ផែនការគ្រប់គ្រងសហគមន៍នេសាទ.....៧
ក- ទស្សនៈវិស័យ.....៧
ខ- គោលបំណង.....៧
គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍.....៧
ផ្នែកទី១.ការអភិបាលរកិច្ចនិងការគ្រប់គ្រង.....៧
គ១- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ.....៧
គ២- ផែនការប្រជុំប្រចាំខែនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ.....៨
គ៣- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល.....៨
គ៤- ផែនការប្រើប្រាស់ឧបករណ៍នេសាទ.....៩
គ៥- ផែនការទប់ស្កាត់បទល្មើសជលផល.....១០
គ៦- ផែនការកែលម្អកន្លែងនេសាទសហគមន៍.....១១
គ៧- ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ.....១២
គ៨- ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្តាមសេះរបស់សហគមន៍នេសាទ.....១២
គ៩- ផែនការគ្រប់គ្រងព្រៃកោកាង.....១៣
ផ្នែកទី២. សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នេសាទ.....១៤
គ១០- ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍នេសាទ.....១៤
គ១១- ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ.....១៥
គ១២- ផែនការបង្កើតកន្លែងទេសចរណ៍ធម្មជាតិរបស់សហគមន៍នេសាទ.....១៦
គ១៣- ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ.....១៧
ផ្នែកទី៣. **ការចូលរួមរបស់ស្ត្រីនិងយុវជន ការកសាងភាពធននឹងការប្រែប្រួលអាកាសធាតុ**.....១៨
គ១៤- ផែនការផ្សព្វផ្សាយនិងជ្រើសរើសស្ត្រីនិងយុវជនចូលជាសមាជិកសហគមន៍នេសាទ.....១៨
គ១៥- ផែនការកសាងភាពធននឹងការប្រែប្រួលអាកាសធាតុ.....១៨

ផ្នែកទី៤. ការទំនាក់ទំនងនិងគៀងគរធនធាន.....១៩
គ១៦-ផែនការទំនាក់ទំនងនិងគៀងគរធនធាន.....១៩
គ១៧- ផែនការចរិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍.....២០
ឃ- ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ.....២០
ង. ផែនការយុទ្ធសាស្ត្រ.....២១
តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ រយៈពេល៣ឆ្នាំ.....២២
តារាងពេលវេលាការងារ.....២៩

ផែនការគ្រប់គ្រង
កន្លែងនេសាទសហគមន៍

១ ស្ថានភាពទូទៅ

សហគមន៍នេសាទកំពង់សាមគ្គី ស្ថិតនៅភូមិកំពង់ឆ្មោត ឃុំកូនសត្វ ស្រុកទឹកឈូ ខេត្តកំពត ត្រូវបានបង្កើតឡើងដោយមហាសន្និបាតលើកដំបូងនៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៦ បន្ទាប់មកបានចុះបញ្ជីជាផ្លូវការនិងទទួលស្គាល់ដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមប្រកាសលេខ ១២៣ ប្រក.កសក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១១។ សហគមន៍នេសាទនេះរៀបចំបោះឆ្នោតជ្រើសរើសគណៈកម្មការជាថ្មីទៅតាមលក្ខន្តិកៈនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៥ ដោយមានគណៈកម្មការចំនួ១១នាក់ ស្រី៨នាក់ និងមានក្រុមល្បាតចំនួន៧នាក់។ ចំពោះសមាជិកសហគមន៍កន្លងមក សហគមន៍នេសាទកំពង់សាមគ្គី សរុបចំនួន១១០នាក់ ស្រី៦០នាក់ ត្រូវនឹង៤០គ្រួសារ ហើយនាពេលបច្ចុប្បន្ន សមាជិកសហគមន៍នេសាទកើនបានសរុបចំនួន១៩៩១នាក់ ស្រី៩៥៦នាក់។

កន្លងមកសហគមន៍នេសាទកំពង់សាមគ្គី បានរៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដោយបានកំណត់ព្រំប្រទល់ផែនទីកន្លែងនេសាទសហគមន៍ ព្រមទាំងរចនាសម្ព័ន្ធគ្រប់គ្រង ដែលបានបែងចែកតួនាទី និងភារកិច្ចការទទួលខុសត្រូវ របស់គណៈកម្មការ និងសមាជិកសហគន៍ដែលមានការទទួលស្គាល់ឯកភាពពីភាគីពាក់ព័ន្ធទាំងថ្នាក់ជាតិនិងអាជ្ញាធរមូលដ្ឋាន។ ចំពោះផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ គណៈកម្មការនិងសមាជិកសហគមន៍សហការណ៍ជាមួយដៃគូពាក់ព័ន្ធ បានអនុវត្តសកម្មភាពសំខាន់ៗ រួមមាន ចូលរួម ប្រជុំនិងបិទផ្សាយផែនទីកន្លែងនេសាទសហគមន៍ រៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ បង្កើតធនាគារក្តាមសេះ ដើម្បីបង្កើនជលស្តុកក្តាមសេះក្នុងធម្មជាតិ ផ្តួចផ្តើមសកម្មភាពមុខរបរ តាមរយៈសេវាកម្មកសិទេសចរណ៍សហគមន៍ ចូលរួមយុទ្ធនាការផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពនានា រៀបចំក្រុមល្បាតសហគមន៍និងចុះល្បាតដោយសហការជាមួយសមត្ថកិច្ចជលផល អាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទកើតមានក្នុងកន្លែងនេសាទសហគមន៍។ សកម្មភាពទាំងនេះសបញ្ជាក់ពីការប្រឹងប្រែងអនុវត្តសកម្មភាពមានចែងក្នុងផែនការគ្រប់គ្រងរបស់ខ្លួន ទៅតាមធនធានដែលមានកំណត់។ បច្ចុប្បន្នសហគមន៍នេសាទកំពង់សាមគ្គីកំពុងខិតខំគៀងគរការចូលរួមធនធាននិងការគាំទ្រនានាក្នុងការដោះស្រាយបញ្ហា ប្រឈមដែលនៅតែកើតមានឡើងដូចខាងក្រោម៖

- ផលនេសាទថយចុះបណ្តាលពីរសកម្មភាពនេសាទលើសកម្រិត ដោយតម្រូវការកើនឡើង ការប្រើឧបករណ៍នេសាទបំផ្លិចបំផ្លាញ ដូចជាទូកអូស្រទាប់បាតនៅទឹករាក់ ការប្រើប្រាស់ឧបករណ៍ឆក់ជាដើម និងការប្រជែងគ្នាក្នុងការនេសាទរវាងសកម្មភាពនេសាទខ្នាតតូច ប្រពៃណី និងខ្នាតធំ។ សហគមន៍នេសាទសង្កេតឃើញថា ផលចាប់ត្រី និងវារីសត្វសមុទ្រផ្សេងៗថយចុះ
- ការថយចុះប្រព័ន្ធអេកូស៊ីស្តែមជលផលសមុទ្រ ដូចជា ជម្រកជលផលសមុទ្រ ព្រៃកោងកាង ស្មៅសមុទ្រ ផ្កាថ្ម ដែលកំពុងរងផលប៉ះពាល់ពីការនេសាទដែលបំផ្លិចបំផ្លាញ ការអភិវឌ្ឍមិនសមស្រប ជាដើម
- សមត្ថភាពនិងចំណេះដឹងរបស់គណៈកម្មការនិងសមាជិកនៅមានកម្រិត ដូចជា ខ្វះជំនាញបច្ចេកទេសលើការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងការអនុវត្តការងារគ្រប់គ្រងតាមបែបសហគមន៍មូលដ្ឋានឬសហគ្រប់គ្រងនៅមានកម្រិត
- ការជ្រើសរើសមុខរបរមានកម្រិត និងងាយរងគ្រោះ ដោយពឹងផ្អែកលើប្រភពចំណូលតែមួយ និងជលចាប់ពីធម្មជាតិ អស្ថេរភាពតម្លៃផលិតផលកសិកម្មកំណត់ដោយឈ្មួញកណ្តាលក្នុងតំបន់ ពិបាកក្នុងការទទួលបានតម្លៃបន្ថែមលើផលិតផលដោយសារគុណភាពផលិតផលនិងការកែច្នៃ ខ្វះទន់ក្នុងការចាប់ផ្តើម និងជំនាញលើមុខរបរ ដូចជាការបង្កើនសេវាកសិទេសចរណ៍ វារីវប្បកម្មដែលមិនប្រើចំណីជាដើម

- ការប្រែប្រួលអាកាសធាតុនិងគ្រោះធម្មជាតិដែលប៉ះពាល់លើការប្រកបរបរនេសាទ សេវាទេសចរណ៍ លំនៅដ្ឋាន និងគុណភាពទឹកសមុទ្រ ដូចជា កំណើនជាតិពុលក្នុងទឹក កំដៅទឹកសមុទ្រ អាចនឹងប៉ះពាល់ដល់ទេសចរណ៍ និងវារីវប្បកម្ម
- ការបំពុល សំណល់រាវ និងផ្លាស្ទីក បណ្តាលពីការបង្ហូរកាកសំណល់នានាដែលប៉ះពាល់ដល់គុណភាពទឹក សមុទ្រ បង្កឱ្យមានជាតិពុល និងសោភណ្ឌភាពសហគមន៍នេសាទ
- រចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទនៅមានកម្រិត ដូចជា ការងាររដ្ឋបាល ការអនុវត្តសកម្មភាព ការងារគ្រប់គ្រង ការងារសេដ្ឋកិច្ច ការការពារធនធានជលផល និងសកម្មភាពការងារល្បាត
- ការពង្រឹងច្បាប់មានកម្រិត ដោយខ្វះមធ្យោបាយ ដូចជាឧករណ៍ទំនាក់ទំនងវាយការណ៍ ទូកល្បាតដែលធន នឹងអាកាសធាតុ ប្រភពថវិកាគាំទ្រសកម្មភាពល្បាត ការចូលរួមពីសមាជិកមានកម្រិត ការផ្សព្វផ្សាយច្បាប់ ស្តីពីជលផលមិនបានដិតដល់ជាប្រចាំ។

ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទកំពង់សាមគ្គី ឆ្នាំ២០១៧ ដល់ឆ្នាំ២០២២ លេខ១៨៩៤ជធ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០១៧ ត្រូវរៀបចំកែសម្រួលឡើងវិញ ដោយធ្វើបច្ចុប្បន្នភាពនូវទិន្នន័យសហគមន៍នេសាទ សកម្មភាព នានាស្របនឹងនិន្នាការថ្មីៗ តម្រូវការសហគមន៍ និងការប៉ាន់ប្រមាណថវិកា ដោយផ្តោតលើការអភិរក្សជលផល ការបង្កើតមុខរបរការគ្រប់គ្រងសកម្មភាពនេសាទ និងការប្រើប្រាស់ធនធានជលផលនៅក្នុងសហគមន៍នេសាទប្រកប ដោយនិរន្តរភាព និងការចូលរួមចំណែកកាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ស្របតាមប្រការ៣០ នៃប្រកាសលេខ ៣១៦ ប្រក.កសក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំសហគមន៍នេសាទ។

២ អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

ក. ប្រជាសាស្ត្រ

ចំនួនប្រជាពលរដ្ឋសរុបនៅក្នុងសហគមន៍មានចំនួន៤០៣ គ្រួសារ មនុស្សសរុបចំនួន១៩៩១ នាក់ ស្រីចំនួន ៩៥៦ នាក់ ក្នុងនោះមាន៖

- ជនពិការចំនួន២១នាក់ ស្រី១០នាក់
- ចាស់ជរា២៩នាក់ ស្រី២៦នាក់
- កុមារកំព្រា៦នាក់ ស្រី៤នាក់
- អ្នកកាន់សាសនា ព្រះពុទ្ធ១០០%
- អ្នកមិនចេះអក្ស២៤ នាក់
- កម្រិតមត្តេយ្យចំនួន៥៩នាក់ ស្រី២២នាក់
- កម្រិតបឋមចំនួន៣០៧នាក់ ស្រី១៥៦នាក់
- អនុវិទ្យាល័យចំនួន១១៣នាក់ ស្រី៦១នាក់
- វិទ្យាល័យសរុប១០៤នាក់ ស្រី៥៦នាក់
- មហាវិទ្យាល័យ ២២នាក់ ស្រី១០នាក់

ខ. មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទនេះរួមមាន៖

-ធ្វើនេសាទ ចំនួន២១០ គ្រួសារ

-ធ្វើស្រែ ចំនួន៤០ គ្រួសារ

-ដាំបន្លែ ចំនួន២០ គ្រួសារ

-លក់ដូ ចំនួន២០ គ្រួសារ

-ចិញ្ចឹមសត្វ ចំនួន១០គ្រួសារ

-កម្មករ ចំនួន២១៥នាក់

-ចំណាកស្រុកក្រៅប្រទេសចំនួន៨ គ្រួសារ

៣ កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

ក. ទីតាំង

កន្លែងនេសាទសហគមន៍កំពង់សាមគ្គី ជាដែននេសាទតំបន់ឆ្នេរសមុទ្រមានទំហំ ៥៧៧.៩០ ហិកតា និងមានកំណត់ និយាមការដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹងស្រែអំបិល
- ខាងត្បូងទល់នឹងសមុទ្រ
- ខាងកើតទល់នឹងសហគមន៍នេសាទអូរក្រសារ
- ខាងលិចទល់នឹងសហគមន៍នេសាទត្រពាំងសង្កែ។

ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍កំពង់សាមគ្គី ជាដែននេសាទតំបន់ឆ្នេរ ។

នៅតាមដែននេសាទសហគមន៍ប្រជាពលរដ្ឋទៅរកនេសាទដោយប្រើប្រាស់ឧបករណ៍នេសាទនិងរដូវនេសាទដូចខាងក្រោម ៖

១. មងត្រី

២. មងក្តាម

៣. សន្ទូចអូសមឹក

៤. ឈិបរុញដៃ

៥. លបក្តាម

៦. លូកក្តាមថ្ម

៧. រាវបង្គា ក្រែង(ក្រែងឈាម ក្រែងមាត់រៀច)

៨. ឆ្នុះបង្គា

៩.សំណាញ់

១០.រីសសារាយ

គ. តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្សជលផល

កន្លែងអភិរក្សព្រៃកោងកាងទំហំ ៧២ ហិកតា និងស្មៅសមុទ្រទំហំ ៥០ហិកតា។

ឃ. ធនធានជលផល

ប្រភេទត្រីសមុទ្រ ៖ ត្រីស ត្រីក្បាលហែង ត្រីក្អកស ត្រីអាំងកើយ ត្រីបេកា ត្រីតុកកែ ត្រីចាប ត្រីអង្រៃ ត្រីកិ ត្រីពូច ត្រីចង្កូមបី ត្រីគ្គចិន ត្រីក្អក ត្រីកាម៉ុង ត្រីម្រេច ត្រីស្តង់ ត្រីផ្លោង ត្រីឆ្លាម ត្រីប្រលួស ត្រីក្អក ត្រីក្អកក្បាលស្រួច ត្រី អាម៉ក់ ត្រីបបែល ត្រីអណ្តាតឆ្កែ ត្រីមួយ ត្រីកន្ទុយក្រហម ត្រីអង្រៃ ត្រីកន្ទុយបី ត្រីឆ្នារ ត្រីកំពត ត្រីខែ ត្រីគោ ត្រី សមុទ្រទៃ ត្រីប្រកង ត្រីចាបស ត្រីចាបខ្មៅ ត្រីការ៉ាវ ត្រីត្រចៀកដំរី ត្រីដូអង្គរ ត្រីផ្កសមុទ្រ ត្រីអណ្តែងប៉ុយត្រីប្រម៉ា ត្រីកន្ទុយក្របី ត្រីកខ្លាំង ត្រីស្លឹកឬស្សី ត្រីកន្ទុយរឹង ត្រីអណ្តែងខ្លុយ.....។ល។

ប្រភេទវារីសត្វសមុទ្រ ៖ បង្គា ក្តាមសេះ ក្តាមថ្ម ក្តាមជ័រ ក្តាមព្រលិត ក្តាមផ្គលាន់ អន្ទុងសមុទ្រ មឹក បង្កងកណ្តូប ខ្យងត្របួន ខ្យងកំបោរ ខ្យងចាក់ចែង ខ្យងភ្នែកប្រើស ខ្យងដែកគោល ខ្យងត្នោត ខ្យងដូង ខ្យងដីរី ខ្យងចំពុះទា ខ្យងផ្ទិត ខ្យងចប ជីក ខ្យងបន្លា ខ្យងផ្ទើប្រាណ ខ្យងរៀចមាត់ ខ្យងតាឱត ខ្យងជើងមួយ ខ្យងដែក ខ្យងគ្រាល ខ្យងក្តស្វា ងាវភក់ ងាវមាន់ ងាវខ្លុយ គុំសុភី គ្រំក្រឡាហូល គ្រែងឈាម បង្កងប៉ាក អន្ទង់ ខឹង ក្រាសសមុទ្រ និងប្រភេទសត្វជិតផុត ពូជ (គ្រំយក្ស កញ្ចា ផ្សោតខ្មៅ ផ្សោតប៉ាវ៉ា បង្ក្រាប) ។

ប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិ៖ ដើមត្រចៀកក្រាញ់ ប្រង់ ក្រចកនាង ក្បាញស ក្បាញ ក្បាញខ្មៅ បាសាក់ បាសាក់ក្រហម បាសាក់ខ្មៅ បាសាក់សប្មរំផ្លោង ស្អែក្រហម ស្នែស ឈើជ័រ សេមាន់សមុទ្រ ក្រញឹបក្រហម ក្រញឹបស ចាក កោងកាងស្លឹកតូច កោងកាងស្លឹកធំ ក្រញឹបឈ្មោល អំពូថ្ម អំពូលក្រហម អំពារ ម្លូជ្ជា វ័ល្អប្រេងសមុទ្រ វ័ល្លពោះត្រី វ័ល្អរេបុផ្តៅស្វា បាសប្មកបាសសមុទ្រ វ័ល្អត្រកួនទឹកសមុទ្រ រំចេក ព្រះអន្លក់ ត្រចៀក ព្រឹសសមុទ្រ អណ្តាតពោះ និងដើមពោធ៏សមុទ្រ សារាយ ផ្ទូកទឹក អាតឹង កាឈៀវ...។ល។

៤. ការធ្វើនេសាទ

ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន២១០នាក់ ស្រី៣០នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍២៥៦គ្រួសារ
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន២០០នាក់ ស្រី១៣១នាក់ ក្នុងមួយឆ្នាំ។

ខ. ឧបករណ៍នេសាទ

- ឧបករណ៍នេសាទនិងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ៖

ប្រភេទ ឧបករណ៍	ឯកតា	ចំនួន គ្រួសារ	ចំនួន ឧបករណ៍នេសាទ	ទំហំ/ប្រវែង	រដូវនេសាទ
មងត្រី	ម៉ែត្រ	១០	១ផែ/គ្រួសារ	៥០០	១ឆ្នាំ
មងក្តាម	ម៉ែត្រ	៨	១៥០០ម/គ្រួសារ	១៥០០ ក្រឡា៦ស.ម ឡើងក្រឡា៦ស.ម ឡើង	១ឆ្នាំ
សន្ទូចមឹក	ផ្លែ	២០	១៥០ផ្លែ/គ្រួសារ	១៥០	១ឆ្នាំ
ឈិបរុញដៃ	គ្រឿង	៥០	១គ្រឿង/គ្រួសារ	៥០	១ឆ្នាំ
លបក្តាម	លប	៣	៥០០លប/គ្រួសារ	ក្រឡា ៦ស.ម ឡើង	១ឆ្នាំ
លូកក្តាមថ្ម	នាក់	១៥	១៥	១៥	១ឆ្នាំ
រាវបង្គាក្រែង(ក្រែងឈាម ក្រែងមាត់រៀច)	នាក់	៣០	៣០	៣០	១ឆ្នាំ
ឆ្លុះបង្គា	គ្រឿង	៥០	១គ្រឿង/គ្រួសារ	ប្រវែង១.៥ម និងផ្លែ៧	ខែតុលា-ខែមីនា
សំណាញ់	ម៉ែត្រ	១០	១វង់/គ្រួសារ	៤៥០ម	១ឆ្នាំ

រើសសារាយ	នាក់	៥	៥	៥	ខែតុលា-ឧសភា

(ស.ម = សង្ខឹម៉ែត្រ, ម = ម៉ែត្រ)

ប្រភេទទូក កាណូត	ចំនួន	ចំណុះ	កំលាំងសេះ
ទូកម៉ាស៊ីនបន្តើត	៤០គ្រឿង	១.០០០-១.៥០០គីឡូក្រាម	៦-១៨ សេះ
អូប័រ	២គ្រឿង	៥០០គីឡូក្រាម	៥-៨សេះ

ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ ៖

ឧបករណ៍នេសាទ	ឯកតា	ចំនួនគ្រួសារ	ចំនួនឧបករណ៍នេសាទ	ទំហំ/ប្រវែង	រដូវប្រើប្រាស់ឧបករណ៍ (ខែ.ដល់ខែ.)
មងក្តាម	ម៉ែត្រ	៥	១ផៃ/គ្រួសារ	១៥០០ម	១ឆ្នាំ
សំណាញ់	វង់	៣	១វង់/គ្រួសារ	វង់	១ឆ្នាំ

(ម = ម៉ែត្រ)

ប្រភេទទូក កាណូត	ចំនួន	ចំណុះ	កំលាំងសេះ
ទូកម៉ាស៊ីនបណ្តើត	៥គ្រឿង	១.០០០-១.៥០០គីឡូក្រាម	៦-១៨ សេះ

ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍៖

ប្រភេទឧបករណ៍	ឯកតា	ចំនួននាក់	ចំនួនឧបករណ៍នេសាទ	ទំហំ/ប្រវែង	រដូវប្រើប្រាស់ឧបករណ៍ (ខែ.ដល់ខែ.)
មងត្រី	ម៉ែត្រ	៥០	១ផៃ/គ្រួសារ	១៥០០ម	១ឆ្នាំ
សំណាញ់	វង់	៤	១វង់/គ្រួសារ	៤៥០ម	១ឆ្នាំ
សន្ទូចរនង (អណ្តែងប៉ុយ ត្រីក្អុក)	ផ្លែ	៥	១ផ្លែ/គ្រួសារ	៣០០	ខែឧសភា-ខែតុលា
លូកក្តាមថ្ម ក្តាមជ័រ	នាក់	១០	១០	១០	១ឆ្នាំ
ឈិបរុញដៃ	គ្រឿង	២០	១គ្រឿង/គ្រួសារ	៥ម×៦ម	១ឆ្នាំ
ឆ្នុះបង្គារ	គ្រឿង	៥០	១គ្រឿង/គ្រួសារ	ស្មមុខ៥×១.៥ម	ខែតុលា-ខែមីនា
រើសសារ៉ាយ	នាក់	៣០	៣០	៣០	ខែតុលា-ខែឧសភា

ប្រភេទទូក កាណូត	ចំនួន	ចំណុះ	កំលាំងសេះ
ទូកម៉ាស៊ីនបណ្តើត	៣០ គ្រឿង	១000-១៥00 គីឡូក្រាម	៦-១៨ សេះ

គ. ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

ប្រភេទផលនេសាទ	បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គ្រួសារអ្នកនេសាទ)		
	រដូវប្រាំង	រដូវវស្សា	សរុបប្រចាំឆ្នាំ
ត្រីគ្រប់ប្រភេទ	៨00 គីឡូក្រាម	៣00 គីឡូក្រាម	៧00 គីឡូក្រាម
ក្តាម	៦00 គីឡូក្រាម	៥00 គីឡូក្រាម	១១00 គីឡូក្រាម

៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

ក. ទស្សនៈវិស័យ

សហគមន៍នេសាទកំពង់សាមគ្គី មានទស្សនៈវិស័យចូលរួមគ្រប់គ្រងធនធានជលផលសមុទ្រប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទសមុទ្រ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទកន្លែងនេសាទសហគមន៍ នាទីព្រៃកោងកាង និងនាទីទឹកជោរនាច
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ និងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ ។

គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ផ្នែកទី១. ការអភិបាលរកិច្ចនិងការគ្រប់គ្រង

គ១. ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ

ផែនការជួសជុលស្នាក់ការសហគមន៍នេសាទ ចំណុចនិយាមកា 417806 – 1168333 ដែលមានទីតាំងនៅភូមិកំពង់ត្នោត ឃុំពងសត្វ ស្រុកទឹកឈូ ខេត្តកំពត។

សកម្មភាព	លទ្ធផលរំពឹងទុក	ប៉ាន់ប្រមាណតម្លៃ (ដុល្លារ)	អ្នកចូលរួម	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
ប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាពនិងអ្នកពាក់ព័ន្ធ	-មានការចូលរួម -មានការគាំទ្រ	៥០០	សហគមន៍នេសាទ ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ	មេសា ២០២៦	មិថុនា ២០២៦
សាងសង់ស្នាក់ការសហគន៍នេសាទ ទំហំ៨មx១៥ម ធ្វើពីបេតុង រួមផ្សំគ្រឿងឈើ ប្រក់ស៊ីប្រូ បន្ទប់មួយ រៀបជញ្ជាំងឈើ	-ស.ន មានកន្លែងធ្វើការ -មានលទ្ធភាពពេញលេញក្នុងការការពារ គ្រប់គ្រងកន្លែងនេសាទសហគមន៍	២០០០០		មេសា ២០២៦	មិថុនា ២០២៦
ទិញសម្ភារៈ (តុ២ ទូ១ ក្តារខៀន១ កៅអីជរ ៥០ កុំព្យូទ័រ១ ព្រីនធឺ១)	មានសម្ភារសម្រាប់ធ្វើការ	១០០០០		មេសា ២០២៦	មិថុនា ២០២៦

គ២. ផែនការប្រជុំនិងទិញសម្ភារអនុវត្តន៍ការងាររបស់គណៈកម្មការសហគមន៍នេសាទ

ផែនការប្រជុំនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម ៖

សកម្មភាព	លទ្ធផលរំពឹងទុក	ប៉ាន់ប្រមាណតម្លៃ(ដុល្លារ)	អ្នកចូលរួម	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
ប្រជុំគណៈកម្មការសហគមន៍នេសាទ សប្តាហ៍ទី១នៃខែរៀងរាល់ខែឬត្រីមាស	-របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ -មានផែនការណ៍អនុវត្តន៍បន្ត	៦៦០	-គណៈកម្មការ -ក្រុមល្បាត	កញ្ញា ២០២៥	សីហា ២០២៨
ចូលរួមប្រជុំជាមួយអាជ្ញាធរសង្កាត់ក្រុង ឬអង្គភាពពាក់ព័ន្ធ	-ទទួលព័ត៌មាន និងផ្តល់របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ -បញ្ចូលផែនការណ៍ជាមួយ	៦៥០	-អាជ្ញាធរសង្កាត់ -គណៈកម្មការ	កញ្ញា ២០២៥	សីហា ២០២៨
ចូលរួមប្រជុំជាមួយបណ្តាញសហ			-អាជ្ញាធរសង្កាត់	កញ្ញា	សីហា

គមន៍នេសាទថ្នាក់ក្រុង ឬថ្នាក់ខេត្ត	ផែនការអភិវឌ្ឍន៍សង្កាត់ -មានដំណោះស្រាយ		-បណ្តាញស.ន	២០២៥	២០២៨
ចុះអនុវត្តន៍សកម្មភាពជម្រុញការចុះបញ្ជីទូកម៉ាស៊ីន ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន និងជំនាញពាក់ព័ន្ធ ជាប្រចាំ	- បានចុះបញ្ជីទូកម៉ាស៊ីន - ទូកម៉ាស៊ីនធ្វើនេសាទបានដាក់ប្រព័ន្ធតាមដាន -បទល្មើសជលផលថយចុះ	៦០០	គណៈកម្មការអាជ្ញាធរមូលដ្ឋានជំនាញជលផលស្ថាប័នពាក់ព័ន្ធ	កញ្ញា ២០២៥	សីហា ២០២៨
ចុះអនុវត្តន៍សកម្មភាពការប្រមូលព័ត៌មាន ការកត់ត្រាទូកនេសាទ ឧបករណ៍នេសាទ និងផលចាប់ត្រី	-មានព័ត៌មានច្បាស់លាស់ -រៀបចំផែនការបានត្រឹមត្រូវ -ការគ្រប់គ្រងស.នបានល្អ	៩០០	-គណៈកម្មការ -សមាជិកស.ន	កញ្ញា ២០២៥	សីហា ២០២៨
-សម្ភារការិយាល័យ - LCD with Screen -ទិញក្រដាស់ បិច -ព្រីនឯកសារ កូពី -ការទំនាក់ទំនង	មានសម្ភារការិយាល័យសម្រាប់ប្រើប្រាស់	២០០០	គណៈកម្មការ	កញ្ញា ២០២៥	សីហា ២០២៨

(ស.ន = សហគមន៍នេសាទ)

គ៣. ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល

ផែនការផ្សព្វផ្សាយ និងបណ្តុះបណ្តាល ត្រូវបានរៀបចំឡើង ដើម្បីពង្រឹងសមត្ថភាពដល់សហគមន៍នេសាទ មានដូចខាងក្រោម

សកម្មភាព	លទ្ធផលរំពឹងទុក	ប៉ាន់ប្រមាណតម្លៃ(ដុល្លារ)	អ្នកចូលរួម	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
ផែនការផ្សព្វផ្សាយ					
ប្រជុំផ្សព្វផ្សាយស្តីពី ៖ -ច្បាប់ជលផល ឯកសារគតិយុត្តិនានាពាក់ព័ន្ធនឹងស.ន -លក្ខន្តិក: បទបញ្ជាផ្ទៃក្នុងស.ន និងផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ -ការរៀបចំនិងទុកដាក់សម្រាម -បទពិសោធន៍នានាទទួលបាន	-សមាជិកសហគមន៍នេសាទ និងអ្នកខាងក្រៅមានការយល់ដឹង និងអនុវត្តតាម -សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការ និងវិធានច្បាប់នានាដែលបានផ្សព្វផ្សាយ -ផលត្រីនៅក្នុងសហគមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានច្រើននាំឱ្យជីវភាពធូរធារ	២៥៨០	គណៈកម្មការ, សមាជិកស.ន និងអ្នកក្រៅស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល, អង្គការដៃគូ	មីនា-មិថុនា/ រៀងរាល់ឆ្នាំ	
បិទផ្សាយឯកសារ ១ដង/ឆ្នាំ		១៦០		កញ្ញា ២០២៥	សីហា ២០២៨
-ចែកចាយឯកសារផែនការប្រើប្រាស់ឧបករណ៍ដល់អ្នកនេសាទ១ដង/ឆ្នាំ -ចែកចាយឯកសារនានា		៤៥០			
ផ្សព្វផ្សាយដល់សមាជិកសហគមន៍នេសាទ ដើម្បីចុះបញ្ជីទូកម៉ាស៊ីន	សមាជិកសហគមន៍នេសាទបានចុះបញ្ជីទូកម៉ាស៊ីន តាមច្បាប់	៤៥០	គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន	កញ្ញា ២០២៥	សីហា ២០២៨
ផែនការបណ្តុះបណ្តាល					
វគ្គបណ្តុះបណ្តាលពីរបៀបរៀបចំលិខិតរដ្ឋបាល ៖	គណៈសហគមន៍នេសាទ	១៤០០	គណៈកម្មការនិង	កញ្ញា	សីហា

-កំណត់ហេតុ -របាយការណ៍ -គម្រោងស្នើសុំថវិកា -គម្រោងថវិកា និងការគ្រប់គ្រងថវិកាសហគមន៍នេសាទ	សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តន៍បាន ក្នុងការងារជាក់ស្តែង		សមាជិកស.ន អាជ្ញាធរមូលដ្ឋាន	២០២៥	២០២៨
វគ្គបណ្តុះបណ្តាលពីកំព្យូទ័រ	គណៈសហគមន៍នេសាទ(២នាក់)	៣៦០	គណៈកម្មការស.ន	កញ្ញា ២០២៥	សីហា ២០២៨
វគ្គបណ្តុះបណ្តាលវិធីសាស្ត្រការប្រមូលព័ត៌មាន ដោយការកត់ត្រា ទូកនេសាទ ឧបករណ៍នេសាទ និងផលចាប់ត្រី	គណៈកម្មការសហគមន៍នេសាទ បានយល់ដឹង និងអាចអនុវត្តន៍ បានក្នុងការងារជាក់ស្តែង	៨០០	គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន		
វគ្គបណ្តុះបណ្តាលពីការសម្របសម្រួលនិងដោះស្រាយទំនាស់		៤០០	គណៈកម្មការ ជំនាញជលផល	កញ្ញា ២០២៥	សីហា ២០២៨
បណ្តុះបណ្តាលពីសហគ្រិនភាពដល់គណៈការនិងសមាជិកស.ន	ស្ត្រីមានលទ្ធភាពនិងសមត្ថភាព ក្នុងការប្រកបមុខរបរ	៥០០	គណៈកម្មការ សហគ្រិនខ្មែរ	កញ្ញា ២០២៥	សីហា ២០២៨

(ស.ន = សហគមន៍នេសាទ)

គ៤. ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរនូវប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម

ឈ្មោះ/ទីតាំងកន្លែងនេសាទ	ពេលវេលាធ្វើនេសាទ (ខែ)	ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ		
		ប្រភេទ	ទំហំ/ប្រវែង	ចំនួនគ្រួសារ
ដែននេសាទសហគមន៍កំពង់សាមគ្គី	១ឆ្នាំ	មងត្រី	៥០០ម	១០
	១ឆ្នាំ	មងក្តាម	១៥០០ម	៨
	១ឆ្នាំ	សន្ទូចមឹក	១៥០ផ្លែ	២០
	១ឆ្នាំ	ឈិបរុញដៃ	៥០គ្រឿង	៥០
	១ឆ្នាំ	លបក្តាម	៥០០លម	៣
	១ឆ្នាំ	លូកក្តាមឬ	១៥	១៥
	១ឆ្នាំ	រាវបង្គា ក្រែង ក្រែងឈាម ក្រែងមាត់រៀច	៣០	៣០
	ខែតុលា-ខែមីនា	ឆ្នុះបង្គា	ប្រវែង១.៥ម និងផ្លែ៧	៥០
	១ឆ្នាំ	សំណាញ់	៤៥០ម	១០
	ខែតុលា-ឧសភា	រើសសារាយ	៥	៥

គ៥-ផែនការឆប់ស្អាត់បទល្មើសជលផល

ផែនការចុះទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចខាងក្រោម ៖

សកម្មភាព	លទ្ធផលរំពឹងទុក	ប៉ាន់ប្រមាណតម្លៃ(ដុល្លារ)	អ្នកចូលរួម	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
ផ្សព្វផ្សាយ៖ -តាមមេភ្រូ ២៤ដង/ឆ្នាំ -បិទឯកសារ ១ដង/ឆ្នាំ	-មានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទនិងសារៈសំខាន់នៃធនធានជលផល	១៥៦០	សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល	កញ្ញា ២០២៥	សីហា ២០២៨

-ចែកឯកសារ -ប្រជុំផ្សព្វផ្សាយ ១ដង/ឆ្នាំ មិថុនា/រៀងរាល់ឆ្នាំ	-មានការយល់ដឹងពីការគ្រប់គ្រង សហគមន៍នេសាទ -កាត់បន្ថយការប្រើប្រាស់ឧបករណ៍ នេសាទខុសច្បាប់		អង្គការដៃគូ		
ប្រជុំពិភាក្សាគណៈកម្មការ សហគមន៍រៀបចំផែនការ ប្រចាំខែឬឆមាស(មីនានិង មិថុនា/រៀងរាល់ឆ្នាំ)	-គណៈកម្មការទទួលបាន នូវបទពិសោធន៍ល្អៗ -មានផែនការសមស្របជាក់លាក់ ដើម្បីចុះអនុវត្តន៍ការងារ	៣៦០	សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ	កញ្ញា ២០២៥	សីហា ២០២៨
អនុវត្តន៍ផែនការ៖ (រៀបចំកំលាំងចុះបង្ក្រាប ដល់ទីកន្លែងដោយទំនាក់ ទំនងនិងសហការជាមួយ អាជ្ញាធរមូលដ្ឋាន អង្គភាព ពាក់ព័ន្ធនិងអង្គការដៃគូ) (៤ដង/ខែ = ១៤៤/ដង)	-បទល្មើសជលផលថយចុះ និងឈានទៅលុបបំបាត់ ទាំងស្រុង -ធនធានជលផលកើនឡើង -ជីវភាពសមាជិកសហគមន៍ នេសាទធូរធារ	១០៣៦៨	សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ	កញ្ញា ២០២៥	សីហា ២០២៨
មធ្សោបាយនិងសម្ភារ -សាំង និងប្រេងបាត -អាវ ស្បែកជើង មួក អាវភ្លៀង អាវពោង ពិល អាយកូម ម៉ាស៊ីនថត កែវយ៊ិត កាតទូរស័ព្ទ	មានលទ្ធភាពចុះល្បាតដោយ មានប្រសិទ្ធិភាព	៣៣៤៦	សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ	កញ្ញា ២០២៥	សីហា ២០២៨
ទិញទូកស្មាច់និងម៉ាស៊ីនថ្មី ចំនួន២គ្រឿង	មានមធ្សោបាយចុះល្បាត	៤០០០	សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ	កញ្ញា ២០២៥	សីហា ២០២៨
កៀងគរថវិកាក្នុងការ ឧបបត្ថម្ភ ឬបដិភាគដល់ ប្រជានេសាទដែលឈប់ឬ ផ្លាស់ប្តូរការប្រើឧបករណ៍ នេសាទខុសច្បាប់ ដែល បំផ្លិចបំផ្លាញ	កាត់បន្ថយការប្រើប្រាស់ឧបករណ៍ នេសាទខុសច្បាប់	៥០០០		កញ្ញា ២០២៥	សីហា ២០២៨

ឆ៦- ផែនការកែលម្អកន្លែងនេសាទសហគមន៍

ផែនការកែលម្អដែននេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

ដែននេសាទ	ទំហំ (ហិកតា)	ទំហំដែលត្រូវកែលម្អ	សកម្មភាព	ប៉ាន់ប្រមាណតម្លៃ(ដុល្លារ)	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
ព្រែកផ្លូវទូក	១០០០ ម	២០មX២ ០០ម	ជួលគេបូមព្រែក	៣០០០	មេសា ២០២៦	មិថុនា ២០២៦
ថ្នាលបណ្តុះបណ្តាលក្បែចំណតឡាន			បណ្តុះកូនកោងកាង៣០០០០ដើម	៣៧៥០	មីនា ២០២៦	មីនា ២០២៨

ខូសត្រឡោក	៧២ហិកតា	២.៥ហិកតា	ដាំកូនកោងកាង៣០០០០ដើម	៧៥០០	ឧសភា ២០២៦	ឧសភា ២០២៨

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ)

ផ្នែក៧. ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ

ឈ្មោះដែននេសាទ	ទំហំត្រូវអភិរក្ស (ហិកតា)	ប្រភេទនៃការអភិរក្ស	សកម្មភាព	ប៉ាន់ប្រមាណតម្លៃ(ដុល្លារ)	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
ឃ្លុកខ្ពុយ 417055-1166113 417487-1165616 416889-1164845 416640-1165068	៥០	ស្មៅសមុទ្រ	ផ្សព្វផ្សាយពីកន្លែងអភិរក្សស្មៅសមុទ្រដល់ប្រជានេសាទបានដឹង	៤៥០	មីនា ២០២៦	មីនា ២០២៦
			ចុះរកទីតាំងជាក់ស្តែងតាមនិយាមការ	៣០០	មីនា ២០២៦	មីនា ២០២៦
			បោះបង្គោលព្រំកន្លែងអភិរក្សជលផលធ្វើពីស៊ីម៉ង់ចំនួន ១០០ បង្គោល(៤មX០.២ម)	៣០០០	កក្កដា ២០២៦	កញ្ញា ២០២៦
			ដាក់ស្លាកសញ្ញាចំនួន ៦ស្លាក (១មX០.៥ម)	១៥០	មេសា ២០២៦	មិថុនា ២០២៦
			ទិញអំពូលភ្លើងសំគាល់ចំនួន ៦	២០០	មេសា ២០២៦	មិថុនា ២០២៦

ផ្នែក៨- ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្តាមសេះរបស់សហគមន៍នេសាទ

ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្តាមសេះ ត្រូវរៀបចំឡើងដើម្បីបង្កើនផលស្តុកធម្មជាតិនៃធនធានជលផល ដូចមាននៅក្នុងតារាងខាងក្រោម៖

ឈ្មោះដែននេសាទ	ទំហំ	ប្រភេទនៃការអភិរក្ស	សកម្មភាព	ប៉ាន់ប្រមាណតម្លៃ(ដុល្លារ)	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
កន្លែង សហគមន៍នេសាទ កំពង់សាមគ្គី ទំហំ០.៥ហិកតា 418026- 1168026 417995- 1167988 418063- 1167932 418093- 1167964	៥០មx៥០ម	-ស្មៅសមុទ្រ -ក្តាមសេះ -ជីវចម្រុះ	ផ្សព្វផ្សាយដល់ប្រជានេសាទឱ្យបានទូលំទូលាយដើម្បីប្រមូលក្តាមសេះពង	៣៦០	កញ្ញា ២០២៥	សីហា ២០២៨
			សាងសង់ស្ថានីយ៍១កន្លែង ៣មx៤ម និងស្ពានដើរជុំវិញស្ថានីយ៍ធ្វើពីគ្រឿងឈើ និងសម្ភារជាង	១២០០០		
			បោះបង្គោលព្រំកន្លែងការពារក្តាមសេះ និងព័ទ្ធស្បៃមុង	៨០០		
			ពង្រាយប្រអប់សិប្បនិម្មិតធ្វើពីបេតុងចំនួន៥០ ប្រអប់	៥០០០		
			ដាក់ស្លាកសញ្ញាចំនួន២ស្លាក	២០០		
			ព្រលែងកូនក្តាម និងមេក្តាមពង	៥០០		
			ថែទាំ និងប្រមូលផល	១០០		

			ឧបករណ៍សម្ភារគាំទ្រសកម្មភាពភ្ញាស់	៥០០		

(ម = ម៉ែត្រ)

គ៩- ផែនការគ្រប់គ្រងព្រៃកោងកាង និងស្តារឡើងវិញ

ផែនការគ្រប់គ្រងកោងកាង ត្រូវបានរៀបចំឡើងវិញ ដូចមាននៅក្នុងតារាងខាងក្រោម៖

ឈ្មោះផែនេសាទ	ទំហំ (ហ.ត)	ប្រភេទព្រៃឈើការពារ	សកម្មភាព	ប៉ាន់ប្រមាណតម្លៃ(ដុល្លារ)	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
គ្រប់គ្រងកោងកាង 418098-1168018 418140-1168073 418267-1167607 418543-1167118 418777-1167491 419673-1166239 419646-1166569 417790-1168161	៧២	ព្រៃកោងកាង	ផ្សព្វផ្សាយពីកន្លែងព្រៃកោងកាងដល់ប្រជាពលរដ្ឋពលរដ្ឋក្នុងសហគមន៍នេសាទនិងអ្នកមកពីក្រៅ	៤០០	មេសា ២០២៦	មិថុនា ២០២៦
			បោះបង្គោលព្រំប្រទល់ព្រៃកោងកាង ធ្វើពីបេតុង ១៥ស.ម x ១,៥ម ចំនួន ៧០ ដោយសរសេរអក្សរ ព្រំប្រទល់ព្រៃកោងកាងសហគមន៍នេសាទ	១000	មេសា ២០២៦	មិថុនា ២០២៦
			ដាក់ស្លាកសញ្ញាស្តីពីផែនទីព្រៃកោងកាង៤ស្លាក ១ម x ១,៥ម ធ្វើពីគ្រឿងដែក សរសរដែកមូលក្រាស់ ចាក់បេតុង	៨០០	មេសា ២០២៦	មិថុនា ២០២៦

ផ្នែកទី២. សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នេសាទ

គ១០- ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ

ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

សកម្មភាព	លទ្ធផលរំពឹងទុក	ប៉ាន់ប្រមាណតម្លៃ (ដុល្លារ)	អ្នកចូលរួម	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
១.ផែនការបណ្តុះបណ្តាល					
ចិញ្ចឹមគ្រែងឈាម	-មានចំណេះដឹងចិញ្ចឹមគ្រែងឈាម -យកទៅអនុវត្តជាក់ស្តែងបាន	៩០០	គណៈកម្មការនិងសមាជិកស.ន	កញ្ញា ២០២៥	សីហា ២០២៨
ចិញ្ចឹមក្តាមថ្ម	-មានចំណេះដឹងចិញ្ចឹមក្តាមថ្ម -យកទៅអនុវត្តជាក់ស្តែងបាន	៩០០	គណៈកម្មការនិងសមាជិកស.ន		
ចិញ្ចឹមត្រីឆ្តង់ និងត្រីទឹកកែ	-មានចំណេះដឹង -មានមុខរបរ -បង្កើនប្រាក់ចំណូល	៩០០	គណៈកម្មការនិងសមាជិកស.ន		
កែច្នៃផលនេសាទ		៩០០			
បច្ចេកទេសដាំបន្លែ		៩០០			
បច្ចេកទេសកំណត់អាទិភាពជម្រើសមុខរបរ	-មានចំណេះដឹង -មានមុខរបរខ្នាតតូច ឬសិប្បកម្ម -បង្កើនប្រាក់ចំណូល	៩០០	គណៈកម្មការនិងសមាជិកស.ន		
ជំនាញវិជ្ជាជីវៈលើការផ្តល់សេវាទេសចរណ៍ជលផល	-ក្រុមចុងភៅ -ក្រុមផ្ទះស្នាក់នៅ	១ ០០០	គណៈកម្មការនិងសមាជិស.ន		

២.ទស្សនៈកិច្ចសិក្សា	-ក្រុមដឹកជញ្ជូន -ក្រុមផ្ទៀរយានយន្ត -ក្រុមផ្គត់ផ្គង់ផលកសិកម្ម -ក្រុមរោងលម្ហែ (កញ្ចុះ)	២ ៥០០	គណៈកម្មការនិង សមាជិស.ន	កញ្ញា ២០២៥	សីហា ២០២៨
បណ្តុះបណ្តាលពីសហគ្រិនភាពដល់គណៈកម្មការ និង សមាជិកស.ន	គណៈកម្មការ និងស្ត្រីមានមានការយល់ដឹងពីសហគ្រិនភាពប្រមាណ ២០ភាគរយ និងអាចអនុវត្តន៍ក្នុងសកម្មភាពសេដ្ឋកិច្ច និងអាជីវកម្ម	៥០០		កញ្ញា ២០២៥	សីហា ២០២៨
៣.ផែនការបង្កើតក្រុមមុខរបរ					
ក្រុមចិញ្ចឹមគ្រែងឈាម ក្រុមចិញ្ចឹមក្តាមថ្ម	-មានក្រុមចិញ្ចឹមគ្រែងឈាម ក្តាមថ្ម -មានគ្រែងឈាម ក្តាមផ្គត់ផ្គង់ទីផ្សារ -មានមុខរបរនិងប្រាក់ចំណូល	៥០០	គណៈកម្មការនិង សមាជិស.ន	កញ្ញា ២០២៥	សីហា ២០២៨
ក្រុមចិញ្ចឹមត្រីឆ្តង់ និងត្រីតុំតែ	-មានក្រុមចិ.ត្រីឆ្តង់ កង្កែប អន្ទង់ សត្វ -មានបន្លែផ្គត់ផ្គង់ដល់កន្លែងទេសចរណ៍ជលផលនិងទីផ្សារ -មានមុខរបរនិងប្រាក់ចំណូល	៥០០	គណៈកម្មការនិង សមាជិស.ន		
ក្រុមកែច្នៃជលនេសាទដោយផ្តោតលើ ៖ -ក្រុមស្ត្រី -ជនងាយរងគ្រោះក្នុងស.ន	-មានក្រុមកែច្នៃជលនេសាទ -មានផលិតផលជលផលផ្គត់ផ្គង់ដល់ទេសចរណ៍ជលផលនិងទីផ្សារ -មានមុខរបរនិងប្រាក់ចំណូល	៥០០	គណៈកម្មការនិង សមាជិស.ន	កញ្ញា ២០២៥	សីហា ២០២៨
ក្រុមដាំបន្លែ	-មានក្រុមដាំបន្លែ -មានបន្លែផ្គត់ផ្គង់តម្រូវការ -មានមុខរបរនិងប្រាក់ចំណូល	៥០០	គណៈកម្មការនិង សមាជិស.ន		

គ១១-ផែនការអភិវឌ្ឍន៍ទារីវប្បកម្មក្នុងសហគមន៍ឆេសាធ

ផែនការសម្រាប់អភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម

ប្រភេទវារីវប្បកម្ម	ចំនួន	ប្រភេទកូនត្រីពូជ	បរិមាណកូនត្រីពូជ	ប៉ាន់ស្មានតម្លៃ(ដុល្លារ)	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ ប្រមូលផល
ក្រុមចិញ្ចឹមត្រីឆ្តង់ តាមបែរ២០បែរ	២០បែរx៤ម×៣ម×២ម	ត្រីឆ្តង	២៤០០០	១៦៦៦០	កញ្ញា ២០២៥	សីហា ២០២៨
	សាងសង់បែរ		-			
ក្រុមចិញ្ចឹមត្រីទឹកតែ តាមបែរ១០បែរ	១០បែរx៤ម×៣ម×២ម	ត្រីទឹកតែ	១២ ០០០	៨៣៣០		
	សាងសង់បែរ		-			
ក្រុមចិញ្ចឹមត្រីផ្នត់សមុទ្រ ១០បែរ	១០បែរx៤ម×៣ម×២ម	ត្រីផ្នត់សមុទ្រ	១២ ០០០	៨៣៣០	កញ្ញា ២០២៥	សីហា ២០២៨
	សាងសង់បែរ		-			
ក្រុមចិញ្ចឹមត្រីអាំងកឹយ ១០បែរ	១០បែរx៤ម×៣ម×២ម	ត្រី អាំងកឹយ	១២ ០០០	៨៣៣០		
	សាងសង់បែរ		-			
ចិញ្ចឹមកង្កែប អន្ទង់ តាមអាង ឬតង់ (៤គ្រួសារ)	២តង់x២ម×១,៥ម×១,២ម	អន្ទង់	៣ ៦០០	៧២០		
	២តង់x២ម×១,៥ម×១,២ម	កង្កែប	៣ ៦០០	៧២០		
	សាងសង់អាង ឬទិញតង់		-	២៤០០		

ក្រុមចិញ្ចឹមបង្កង កន្លូប (បង្កងលេខ)	១០បែរx៤មx៣មx២ម	បង្កងកន្លូប	៦ ០០០	៨០០០	កញ្ញា ២០២៥	សីហា ២០២៨
	សាងសង់បែរ		-			
ក្រុមចិញ្ចឹមត្រីឆ្ពង់ តាមបែរ៣០បែរ	៣០បែរx៤មx៣មx២ម	ត្រីឆ្ពង់	២៤ ០០០	១៦ ៦៦០	មីនា ២០២៦	មីនា ២០២៨
	សាងសង់បែរ		-			
ចិញ្ចឹមគ្រែងឈាម ទំហំ៣ ហិកតា 417866- 417905 417970- 1167778 418059- 1167896 417884- 1168071	ប្រជុំផ្សព្វផ្សាយ	គ្រែងឈាម	-	២០០	មីនា ២០២៦	ធ្នូ ២០២៨
	បង្គោលឈើចម្រុះ ២០០ ដើម x ៨០០០រៀល		-	៨០០		
	របាំងសាច់អួន		-	១ ៥០០		
	កូនពូជគ្រែងឈាម		៥០០គ.ក	១ ៨០០		
	បង្គោលឈើចម្រុះ ២៥០ ដើម x ៨០០០រៀល		-	៥០០		
	របាំងសាច់អួន		-	១ ៥០០		
ក្រុមចិញ្ចឹមក្តាមថ្ម 417779 1168244 417787 1168241 417784 1168226 417774 1168229	ប្រជុំផ្សព្វផ្សាយ	ក្តាមថ្ម	-	២០០	កុម្ភៈ-កក្កដា ២០២៦	កុម្ភៈ-កក្កដា ២០២៨
	ជីកប្រឡាយព័ទ្ធជុំវិញ ០,៥ម x ០,៥ម		-	កម្លាំងពលកម្ម		
	ចិទបាំងហ្វីហ្សូស៊ីម៉ង់ ជុំវិញ ចំនួន ៣២០ សន្លឹក		-	២៥០		
ក្រុមចិញ្ចឹមខ្យងចំពុះទា៥ហិកតា 417972- 1167774 418063- 1167898 418181- 1167700 418109- 1167598 418197- 1167478 418268- 1167563	ប្រជុំផ្សព្វផ្សាយ	ខ្យងចំពុះទា និងអយស្ទ័រ	-	២០០	មីនា ២០២៦	ធ្នូ ២០២៨
	បង្គោលឈើចម្រុះ៥០០ជុំរុំ (ជុំរុំ/៥ដើម x ៦០០០រៀល)		-	៣ ៧៥០		
	ខ្សែចងទីតាំងចិញ្ចឹមខ្យងចំពុះទានិងអយស្ទ័រ		-	១០០		
	កូនពូជខ្យងចំពុះទានិងអយស្ទ័រ		៤០០គ.ក	៣០០		

(ស.ន = សហគមន៍នេសាទ, ម = ម៉ែត្រ, គ.ក = គីឡូក្រាម)

ក១២. ផែនការអភិវឌ្ឍន៍កន្លែងទេសចរណ៍ជលផលរបស់សហគមន៍នេសាទ

ផែនការអភិវឌ្ឍន៍កន្លែងទេសចរណ៍ជលផលរបស់សហគមន៍នេសាទ ត្រូវបានរៀបចំឡើងនៅតាមឆ្នេរសមុទ្រ ព្រៃកោងកាង ដងព្រែកនានា និងទេសភាពកន្លែងសហគមន៍នេសាទ មានដូចខាងក្រោម

សកម្មភាព	លទ្ធផលរំពឹងទុក	ប៉ាន់ប្រមាណតម្លៃ (ដុល្លារ)	អ្នកចូលរួម	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
ស្លាកសញ្ញាទីតាំងចំនួន២ (១.៥X២ម)	-មានភ្ញៀវមកច្រើន -ហេដ្ឋារចនាស្អាត -បរិស្ថានស្អាត	៣០០	-គណៈកម្មការ -អាជ្ញាធរ -អង្គការដៃគូ	ត្រីមាសទី១ ឆ្នាំ២០២៦	ត្រីមាសទី១ ឆ្នាំ២០២៦
ទិញខ្សែភ្លើងប្រវែង ២០០០ម		១៥០		ត្រីមាសទី១ ឆ្នាំ២០២៦	ត្រីមាសទី១ ឆ្នាំ២០២៦
សាងសង់កញ្ចុះចំនួន ៥		១០០០០		ត្រីមាសទី៤ ឆ្នាំ២០២៦	ត្រីមាសទី៤ ឆ្នាំ២០២៦
ធុងសម្រាមចំនួន ១០		៣០០		ត្រីមាសទី១	ត្រីមាសទី១

				ឆ្នាំ២០២៦	ឆ្នាំ២០២៦
បង្គន់អនាម័យចំនួន២ខ្នង ៨បន្ទប់ឆ្នាំ២០២៦ត្រីមាសទី ២(ថវិកា១២០០០ដុល្លា)		១២០០០		ត្រីមាសទី ២ ឆ្នាំ ២០២៦	ត្រីមាសទី ២ ឆ្នាំ ២០២៦
ទូកស្មាច់និងម៉ាស៊ីន (៩.២X១.២មX0.៦) ចំនួន៣		១៨០០០		ត្រីមាសទី១ ឆ្នាំ២០២៧	ត្រីមាសទី១ ឆ្នាំ២០២៧
សាងសង់ហេដ្ឋារចនាសម្ព័ន្ធ ស្តានឈើតាមព្រៃកោងកាង ៤០០ម៉ែត្រ (៤X១.២ម)		១៦០០០		ត្រីមាសទី ២ ឆ្នាំ ២០២៧	ត្រីមាសទី ២ឆ្នាំ២០២ ៧
រៀបចំចំណតទូក (ក្បូន) ៣មX ៦ម ប៉ុយចំនួន១២		១០០០		ត្រីមាសទី១ ឆ្នាំ២០២៧	ត្រីមាសទី១ ឆ្នាំ២០២៧

(ស.ន = សហគមន៍នេសាទ)

ផ្នែកទី៣.ការចូលរួមរបស់ស្ត្រីនិងយុវជន ការកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ

គ១៣. ផែនការផ្សព្វផ្សាយជ្រើសរើសចូលជាសមាជិកសហគមន៍នេសាទ

ផែនការផ្សព្វផ្សាយនិងជ្រើសរើសស្ត្រីនិងយុវជនចូលជាសមាជិកសហគមន៍នេសាទ មានដូចខាងក្រោម ៖

សកម្មភាព	លទ្ធផលរំពឹងទុក	ប៉ាន់ប្រមាណតម្លៃ(ដុល្លារ)	អ្នកចូលរួម	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
ធ្វើបច្ចុប្បន្នភាពសមាជិកក្នុងបញ្ជីរសមាជិកសហគមន៍នេសាទ	សមាជិកមានការកើនឡើងទាំងបុរសនិងស្ត្រី	១០០	គណៈកម្មការអាជ្ញាធរមូលដ្ឋាន	ត្រីមាសទី១ ឆ្នាំ២០២៦	ត្រីមាសទី១ ឆ្នាំ២០២៦
ប្រជុំជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ដើម្បីជ្រើសរើសចូលជាសមាជិកសហគមន៍		៥០០	គណៈកម្មការអាជ្ញាធរមូលដ្ឋានប្រជាពលរដ្ឋ	ត្រីមាសទី១ ឆ្នាំ២០២៦	ត្រីមាសទី១ ឆ្នាំ២០២៨

គ១៤. ផែនការកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ

ផែនការកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ ត្រូវបានរៀបចំឡើង ដើម្បីពង្រឹងសមត្ថភាពដល់សហគមន៍នេសាទ មានដូចខាងក្រោម

សកម្មភាព	លទ្ធផលរំពឹងទុក	ប៉ាន់ប្រមាណតម្លៃ (ដុល្លារ)	អ្នកចូលរួម	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
១. ផែនការផ្សព្វផ្សាយ					
ដាំកោងកាង២០០០០ក្នុងឆ្នាំ ផ្ទៃដីដាំ ៧២ហ.ត	ព្រៃកោងកាងមានការកើនឡើង	១០០០០	គណៈកម្មការអង្គការដៃគូអាជ្ញាធរមូលដ្ឋាន	ត្រីមាសទី ២ ឆ្នាំ២០២ ៦	ត្រីមាសទី២ ឆ្នាំ២០២៨
សំអាតអនាម័យ១ខែ៨ដង	បរិស្ថានសហគមន៍ស្អាត	៨០	គណៈកម្មការអង្គការដៃគូអាជ្ញាធរមូលដ្ឋាន	ត្រីមាសទី ១ ឆ្នាំ២០២ ៦	ត្រីមាសទី៤ ឆ្នាំ២០២៨

២. ផែនការបណ្តុះបណ្តាល					
វគ្គបណ្តុះបណ្តាលពី Google map, Avenza maps and GField	គណៈកម្មការស.ន១១នាក់យល់ដឹងពី Google map, Avenza maps and GField	១០០០	គណៈកម្មការស.ន	ត្រីមាសទី ២ ២០២៦	ត្រីមាសទី៣ ២០២៦
ការគ្រប់គ្រងនិងសារៈសំខាន់នៃធនធានធម្មជាតិ	គណៈកម្មការ និងសមាជិកស.ន ប្រជាពលរដ្ឋបានយល់ដឹង និងអាចអនុវត្តន៍ ២០ ភាគរយ	៥០០	គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន	ត្រីមាសទី ៣ ២០២៦	ត្រីមាសទី៣ ២០២៦
វិធានការទប់ស្កាត់ការប្រែប្រួលអាកាសធាតុ	គណៈកម្មការ និងសមាជិក ស.ន ប្រមាណ៥០នាក់ បានយល់ដឹង និងអាចអនុវត្តន៍បានការងារជាក់ស្តែងឆ្លើយតបនឹងការកសាងភាពស៊ាំនៃការប្រែប្រួលអាកាសធាតុ	៥០០	គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន	ត្រីមាសទី ៤ ២០២៦	ត្រីមាសទី៤ ២០២៦

(ស.ន = សហគមន៍នេសាទ)

ផ្លែកទី៤. ការទំនាក់ទំនងនិងការគ្រៀងគរធនធាន និងថវិកា

ក១៥- ផែនការទំនាក់ទំនង និងគ្រៀងគរថវិកា

ផែនការទំនាក់ទំនងនិងគ្រៀងគរថវិកា ត្រូវបានរៀបចំដូចខាងក្រោម

សកម្មភាព	លទ្ធផលរំពឹងទុក	ប៉ាន់ប្រមាណតម្លៃ(ដុល្លា)	អ្នកចូលរួម	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
ផ្សព្វផ្សាយដល់អ្នកនេសាទមិនមែនជាសមាជិកសហគមន៍និងសប្បុរសជនជួយភាគទានសម្រាប់ទ្រទ្រង់ការងារសហគមន៍	សប្បុរសជននឹងអ្នកមិនមែនជាសមាជិកយល់ដឹងនិងចូលភាគទានដល់សហគមន៍	៥០០	-គណៈកម្មការ -សប្បុរសជន -អ្នកនេសាទមិនមែនជាសមាជិក	ត្រីមាសទី១ ឆ្នាំ២០២៦	ត្រីមាសទី៤ ឆ្នាំ២០២៨
ផ្សព្វផ្សាយផែនការគ្រប់គ្រងសហគមន៍ដល់អាជ្ញាធរ អង្គការ និងជំនាញ ដើម្បីជួយគាំទ្រ	អាជ្ញាធរមូលដ្ឋាន អង្គការនិងជំនាញនឹងមានថវិកាជួយគាំទ្រដល់ស.ន	២០០	-គណៈកម្មការ -អាជ្ញាធរមូលដ្ឋាន -អង្គភាពពាក់ព័ន្ធ	ត្រីមាសទី២ ២០២៦	ត្រីមាសទី២ ២០២៦
ប្រជុំបញ្ជាបផែនការគ្រប់គ្រងសហគមន៍នេសាទចូលក្នុងផែនការអភិវឌ្ឍ និងផែនការវិនិយោគសង្កាត់	-បានបញ្ចូលផែនការគ្រប់គ្រងស.ន ចូលក្នុងផែនការអភិវឌ្ឍនិងផែនការវិនិយោគសង្កាត់ -ទទួលបានថវិកាអនុវត្តន៍ការងារ	៦០០	-គណៈកម្មការ -អាជ្ញាធរមូលដ្ឋាន -អង្គភាពពាក់ព័ន្ធ	ត្រីមាសទី២ ២០២៦	ត្រីមាសទី២ ២០២៦

ក១៦. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

សកម្មភាព	លទ្ធផលរំពឹងទុក	ប៉ាន់ប្រមាណតម្លៃ(ដុល្លា)	អ្នកចូលរួម	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
ផ្សព្វផ្សាយផែនការគ្រប់គ្រង	អាជ្ញាធរ ជំនាញ អង្គការដៃគូបានដឹង	៤៥០	សហគមន៍នេសាទ	មីនា	ឆ្ន

សហគមន៍នេសាទដល់អាជ្ញាធរសង្កាត់ ជំនាញ និងអង្គការដៃគូ	ពីផែនការគ្រប់គ្រងស.ន នឹងគាំទ្រដល់ផែនការគ្រប់គ្រងប្រមាណ៩០ភាគរយ		អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ	២០២៦	២០២៨
ធ្វើសមាហរណ៍កម្មផែនការគ្រប់គ្រងសហគមន៍នេសាទចូលក្នុងផែនការអភិវឌ្ឍ និងផែនការវិនិយោគសង្កាត់	-បានបញ្ចូលផែនការគ្រប់គ្រងស.ន ចូលក្នុងផែនការអភិវឌ្ឍនិងផែនការវិនិយោគសង្កាត់ -ទទួលបានថវិកាអនុវត្តន៍ការងារ	៦០០		មីនា ២០២៦	ធ្នូ ២០២៨
កៀងគរថវិកាឧបត្ថម្ភឬបដិភាគដល់ប្រជានេសាទឈប់ឬផ្លាស់ប្តូរការប្រើឧបករណ៍នេសាទខុសច្បាប់	កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ប្រមាណ ៥០ ភាគរយ	៦០០០		មីនា ២០២៦	ធ្នូ ២០២៨

(ស.ន = សហគមន៍នេសាទ)

ឃ. ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ក១៧. ផែនការការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ប្រភេទប្រាក់ចំណូល	សកម្មភាព	ថ្ងៃខែឆ្នាំចាប់ផ្តើម	ថ្ងៃខែឆ្នាំចាប់បញ្ចប់	ចំណូល (ដុល្លារ)	ផ្សេងៗ
ភាគទានសមាជិកភាពសហគមន៍នេសាទ	-ផ្សព្វផ្សាយនិងបង់ប្រាក់សមាជិកភាព -ប្រមូលភាគទាន១០០រៀល/ម្នាក់	មីនា ២០២៦	ធ្នូ ២០២៨	១២	សមាជិកសហគមន៍នេសាទចំនួន២១០នាក់
ភាគទានប្រចាំឆ្នាំ	ផ្សព្វផ្សាយនិងប្រមូលភាគទានប្រចាំឆ្នាំសមាជិកស.ន៥០០រៀល/ម្នាក់			១៨០	សមាជិកសហគមន៍នេសាទចំនួន២៥៦នាក់
ភាគទានពីក្រុមមុខរបររបស់សហគមន៍នេសាទ	- ប្រជុំរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុម -ផ្សព្វផ្សាយនិងប្រមូលភាគទានពីក្រុមមុខរបររបស់សហគមន៍នេសាទ	មីនា ២០២៦	ធ្នូ ២០២៨	ប៉ាន់ប្រមាណ៖	
				៣០០	-៣ក្រុមមុខរបរ គ.១០
				៩០០	-១០ក្រុមមុខរបរ គ.១១
				២៧០០	-១០ក្រុមមុខរបរ គ.១២
				៣០០	-២ក្រុមមុខរបរ គ.១៣
កម្រៃអ្នកនេសាទមិនមែនជាសមាជិកនិងអ្នកមកពីក្រៅ	ប្រមូលប្រាក់កម្រៃពីអ្នកមិនមែនជាសមាជិកនិងអ្នកមកពីក្រៅ២០០នាក់x២០០០រៀល(ពីរម៉ឺនរៀល)/រដូវនេសាទ	មីនា ២០២៦	ធ្នូ ២០២៨	១២០៩០	ប៉ាន់កម្រៃពីអ្នកមិនមែនជាសមាជិកនិងអ្នកមកពីក្រៅ ចំនួន២០០នាក់
គម្រោងស្នើសុំថវិកាពី៖ -រាជរដ្ឋាភិបាល -អង្គការដៃគូរពាក់ព័ន្ធ -សប្បុរសជន	សរសេរគម្រោងស្នើសុំថវិកាពី៖ -មន្ទីពាក់ព័ន្ធក្នុងខេត្ត -អង្គការដៃគូ -តាមដាននិងវាយតម្លៃ	មីនា ២០២៦	ធ្នូ ២០២៨	៣៧១៩៧៧	សរសេរគម្រោងស្នើសុំថវិកាចំណាយ ៥០០ដុល្លារ
សរុបរួម				៣៩៦៥៥៩	

១. ផែនការយុទ្ធសាស្ត្រ

ដើម្បីអនុវត្តន៍ផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តន៍ផែនការរួមមាន សមាជិកគណៈកម្មការសហគមន៍នេសាទចាស់ទុំ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗ ជាពិសេស បញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួល បានការឧបត្ថម្ភគាំទ្របច្ចេកទេសនិងថវិការសម្រាប់ដំណើរការអនុវត្តន៍ផែនការ
- រៀបចំផែនការអនុវត្តន៍ តាមដំណាក់កាលនីមួយៗ ដោយជាក់លាក់ និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទាក់ទងជាមួយរដ្ឋបាលជលផលនិងស្ថាប័នពាក់ព័ន្ធ ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តន៍ផែនការ
- ចូលរួមការស្រាវជ្រាវនានា និងនាំយកឱកាសបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ
- ធ្វើសមាហរណកម្មបញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍សង្កាត់ ។

តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍កំពង់សាមគ្គី រយៈពេល ៣ ឆ្នាំ មីនា ២០២៦ ដល់ ធ្នូ ២០២៨)

ប្រភេទផែនការ	សកម្មភាព	លទ្ធផលរំពឹងទុក	ការប៉ាន់ស្មានចំណាយ	ប្រភពជំនួយ	ពេលផ្តើម	ពេលបញ្ចប់	ផ្សេងៗ
ផ្នែកទី១. ការអភិបាលរកិច្ចនិងការគ្រប់គ្រង							
គ១.ផែនការសាងសង់ស្មាក់ការសហគមន៍នេសាទ	-ប្រជុំជាមួយអ្នកពាក់ព័ន្ធ -សាងសង់ស្មាក់ការ -ទិញសម្ភារសហគមន៍នេសាទ	-ទទួលបានការចូលរួម ការគាំទ្រ -សហគមន៍នេសាទមានការិយាល័យសម្រាប់ធ្វើការ -មានលទ្ធភាពពេញលេញក្នុងការការពារ គ្រប់គ្រងកន្លែងនេសាទសហគមន៍ -មានសម្ភារប្រើប្រាស់ -សម្រេចបានសកម្មភាពការងារ	៣០ ៥០០	- ស.ន.ភ.ថ - រាជរដ្ឋាភិបាល - អង្គការដៃគូ - សប្បុរសជន	មេសា ២០២៦	មិថុនា ២០២៨	
គ២.ផែនការប្រជុំប្រចាំខែនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការស.ន	-ប្រជុំគណៈកម្មការស.ន -ប្រជុំជាមួយស្ថាប័នពាក់ព័ន្ធ -ប្រមូលព័ត៌មាន ការកត់ត្រាទូកនេសាទ ឧបករណ៍នេសាទ និងផលចាប់ត្រី -ទិញសម្ភារការិយាល័យ	-របាយការណ៍លទ្ធផលសម្រេចបានប្រចាំខែ -មានសម្ភារការិយាល័យសម្រាប់ប្រើប្រាស់	៩០០	- ស.ន.ភ.ថ - រាជរដ្ឋាភិបាល - អង្គការដៃគូ - សប្បុរសជន	មីនា ២០២៦	ធ្នូ ២០២៨	
គ៣.ផែនការស្រង់មតិទូក កាណូត ឧបករណ៍នេសាទ និងផលចាប់សហគមន៍នេសាទ	-ប្រជុំរៀបចំបញ្ជីសំណួរ -ស្រង់ស្ថិតិទូក កាណូត និងឧបករណ៍នេសាទ -ស្រង់ស្ថិតិផលចាប់	-មានស្ថិតិទូក កាណូត ឧបករណ៍នេសាទ ច្បាស់លាស់ -មានទិន្នន័យផលចាប់ជាក់លាក់	៦ ៨៦០	- ស.ន.ភ.ថ - រាជរដ្ឋាភិបាល - អង្គការដៃគូ - សប្បុរសជន	កក្កដា ២០២៦	មីនា ២០២៨	
គ៤.ផែនការផ្សព្វផ្សាយបណ្តុះបណ្តាល	-ប្រជុំផ្សព្វផ្សាយច្បាប់ស្តីពីផលផលច្បាប់សហគមន៍កសិកម្ម ឯកសារបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធនឹងស.ន	-មាននិរន្តរភាពធនធានជលផល -សមាជិកប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការនិងវិធានច្បាប់នានាដែលបានផ្ស	៣ ៦០០	សមាជិកនិងគណៈកម្មការ	កក្កដា ២០២៦	មិថុនា ២០២៨	

	ផែនការគ្រប់គ្រងស.ននិង លក្ខន្តិក: បទបញ្ជាផ្ទៃក្នុងស.ន -ផ្សព្វផ្សាយស្តីពី ប្រភេទសត្វ កំពង់រងគ្រោះថ្នាក់ កន្លែងអភិរក្ស	ឲ្យផ្សាយប្រមាណ៥០ភាគរយ -បង្កើនប្រាក់ចំណូលដល់ប្រជា នេសាទស.ន -ផលត្រីនៅក្នុងសហគមន៍ មានការកើនឡើងប្រជាពលរដ្ឋ អាចរកត្រីបានច្រើននាំឱ្យជីវភាព ធូរធារ					
	វគ្គបណ្តុះបណ្តាលស្តីពី៖ -រៀនចំលិខិតរដ្ឋបាល -របាយការណ៍ កំណត់ហេតុ -គម្រោងស្នើសុំថវិកា -សម្របសម្រួលនិងដោះស្រាយទំនាស់ -បណ្តុះបណ្តាលបច្ចេកទេស ចិញ្ចឹមសត្វ ក្រែងឈាម ខ្យងចំពុះទា និងអយស្ទ័រ		២ ៧០០		មេសា ២០២៦	មិថុនា ២០២៨	
គ៥.ផែនការប្រើប្រាស់ ឧបករណ៍នេសាទ	-ធ្វើនេសាទដោយប្រើឧបករណ៍ ស្របច្បាប់ -ប្រើឧបករណ៍នេសាទ ស្របតាមផែនការគ្រប់គ្រង	-មាននិរន្តរភាពធនធានជលផល -បង្កើនប្រាក់ចំណូលដល់ប្រជា នេសាទស.ន	-	សមាជិកនិង គណៈកម្មការ	កក្កដា ២០២៦	មិថុនា ២០២៨	
គ៦.ផែនការទប់ស្កាត់ បទល្មើសជលផលនិង ទិញសម្ភារល្បាត	-ប្រជុំបែកចែកវេនល្បាត -ចុះល្បាត៦ដង/ខែ -មធ្យោបាយនិងសម្ភារ	-មានកម្មវិធីល្បាតតាមវេន -បទល្មើសនេសាទថយចុះនិង ឈានទៅលុបចំបាត់ ទាំងស្រុង -មានលទ្ធភាពចុះល្បាត	៨ ២១២	- ស.ន.ភ.ថ - រាជរដ្ឋាភិបាល - អង្គការដៃគូ - សប្បុរសជន	មេសា ២០២៦	មិថុនា ២០២៨	

		ដោយមានប្រសិទ្ធភាព -មានមធ្យោបាយចុះល្អាត					
គ៧.ផែនការកែលម្អកន្លែងនេសាទសហគមន៍	-ធ្វើផ្លូវទូក (បូមព្រែក) -បណ្តុះកូនកោងកាង ៣០០០០ដើម -ដាំកូនកោងកាង ៣០០០០ដើម	-មានកន្លែងចរាចរណ៍ទូក -ព្រៃលិចទឹកកើនឡើងវិញ -ធនធានជលផលបានគង់វង្ស	១៨ ២៥០	- ស.ន.ភ.ថ - រាជរដ្ឋាភិបាល - អង្គការដៃគូ - សប្បុរសជន	មេសា ២០២៦	មិថុនា ២០២៨	
គ៨.ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផល	-ផ្សព្វផ្សាយឱ្យបានទូលំទូលាយ -ចុះរកទីតាំងជាក់ស្តែងតាមនិយាមកា -បោះបង្គោលព្រំកន្លែងអភិរក្សចលជល -ដាក់ស្លាក់សញ្ញា ៦ស្លាក -ទិញអំពូលភ្លើងសំគាល់ចំនួន៦	-មានទីជម្រកនិងមានត្រីមេពូជ -ត្រីកើនឡើងនិង -ព្រៃលិចទឹកកើនឡើងវិញ -ធនធានជលផលបានគង់វង្ស	៣ ៣៥០	- ស.ន.ភ.ថ - រាជរដ្ឋាភិបាល - អង្គការដៃគូ - សប្បុរសជន	មេសា ២០២៦	មិថុនា ២០២៨	
គ៩.ផែនការគ្រប់គ្រងព្រៃកោងកាង	-ផ្សព្វផ្សាយពីទីតាំងព្រៃកោងកាងឱ្យបានទូលំទូលាយ -បោះបង្គោលព្រំព្រៃកោងកាងនិងដាក់ស្លាកសញ្ញា -ថែរក្សា ការពារ	-ប្រជានេសាទស្គាល់ព្រំប្រទល់ព្រៃកោងកាងបានច្បាស់លាស់ -ព្រៃកោងកាងបានគង់វង្ស -ត្រីមានទីជម្រក -ជីវចម្រុះកើនឡើងវិញ	២ ២០០	- ស.ន.ភ.ថ - រាជរដ្ឋាភិបាល - អង្គការដៃគូ - សប្បុរសជន	មេសា ២០២៦	មិថុនា ២០២៨	
ផ្នែកទី២. សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នេសាទ							
គ១០.ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍	វគ្គបណ្តុះបណ្តាលស្តីពី៖ -ចិញ្ចឹមគ្រែងឈាម អយស្ទ័រ ខ្យងចំពុះទា ត្រីឆ្តង់ មាន់ -កែច្នៃផលនេសាទ -បច្ចេកទេសដាំបន្លែ -បច្ចេកទេសកសិកម្មចម្រុះនិងបន្ត -ទស្សនៈកិច្ចសិក្សា	-មានចំណេះដឹងនិងបច្ចេកទេសលើមុខរបរ -អាចអនុវត្តន៍បានក្នុងការប្រកបមុខរបរ -បន្ថែមប្រាក់ចំណូលដើម្បីលើកកម្ពស់កម្រិតជីវភាព	១២ ០០០	- ស.ន.ភ.ថ - រាជរដ្ឋាភិបាល - អង្គការដៃគូ - សប្បុរសជន	មេសា ២០២៦	មិថុនា ២០២៨	

	បង្កើតក្រុមមុខរបរ ៖ -ក្រុមចិញ្ចឹមគ្រែងឈាម ត្រីឆ្ពង់ -ក្រុមកែច្នៃផលនេសាទ -ក្រុមដាំបន្លែនិងកសិកម្មចម្រុះនិងបន្ត	-មានក្រុមមុខរបរកើតឡើង -មានផលិតផលផ្គត់ផ្គង់ទីផ្សារ -លើកស្ទួយកម្រិតជីវភាព	២ ៥០០	- ស.ន.ភ.ថ - រាជរដ្ឋាភិបាល - អង្គការដៃគូ - សប្បុរសជន	មេសា ២០២៦	មិថុនា ២០២៨	
	ក្រុមបណ្តុះកូនកោងកាង ដើម្បីផ្គត់ផ្គង់ដល់សប្បុរសជន សកម្មភាពទេសចរណ៍និងទីផ្សារ	បណ្តុះកូនកោងកាង ផ្គត់ផ្គង់ដល់សប្បុរសជន និងសកម្មភាពទេសចរណ៍ ចំនួន៣០ ០០០ដើម	៣ ០០០	គណៈកម្មការ និងសមាជិកស.ន.ភ.ថ	មេសា ២០២៦	មិថុនា ២០២៨	
គ១១.ផែនការអភិវឌ្ឍន៍ភាវរីវប្បកម្មក្នុងសហគមន៍នេសាទ	-ចិញ្ចឹមកង្កែប អន្ទង់តាមអាងឬតង់ -ចិញ្ចឹមត្រីឆ្ពង់ក្នុងបែរ -ចិញ្ចឹមគ្រែងឈាម - ចិញ្ចឹមក្តាមសេះ -ចិញ្ចឹមក្តាមថ្ម -ចិញ្ចឹមគ្រំចំពុះទា -ទិញកូនត្រីឆ្ពង់ និងពូជកង្កែប អន្ទង់	-បង្កើតមុខរបរដល់សមាជិកសហគមន៍នេសាទ -មានផលិតផលត្រីផ្គត់ផ្គង់ទីផ្សារ -លើកស្ទួយកម្រិតជីវភាព	២៧ ៣៦០	- ស.ន.ភ.ថ - រាជរដ្ឋាភិបាល - អង្គការដៃគូ - សប្បុរសជន	មេសា ២០២៦	មិថុនា ២០២៨	
គ១២.ផែនការបង្កើតកន្លែងទេសចរណ៍ជលផលរបស់សហគមន៍នេសាទកំពង់សាមគ្គី	-ផ្សព្វផ្សាយឱ្យបានទូលំទូលាយ -ទស្សនៈកិច្ចសិក្សា -រៀបចំទីតាំងទេសចរណ៍ជលផល -សាងសង់ស្លាកសញ្ញាចំនួន២ - សាងសង់កញ្ចុះចំនួន៥ -ធុងសម្រាមចំនួន១០ -បង្គន់អនាម័យចំនួន២ខ្នង ៨បន្ទប់ -ទូកស្មាច់និងម៉ាស៊ីន -សាងសង់ហេដ្ឋារចនាសម្ព័ន្ធ ស្តានឈើតាមព្រៃកោងកាង -រៀបចំចំណតទូក	-ប្រភពចំណូលដល់សហគមន៍នេសាទ -បង្កើតមុខរបរដល់សមាជិកសហគមន៍នេសាទ -មានស្តានឈើតាមព្រៃកោងកាង ៨០០ម៉ែត្រ - មានស្តានភ្ជាប់កន្លែងជម្រុះពងក្តាមសេះ ៨០០ម៉ែត្រ -មានទូកសម្រាប់ល្បាត -មានភ្ញៀវមកកំសាន្ត -មានកញ្ចុះសម្រាប់ភ្ញៀវអង្គុយលេង	៥៧ ៧៥០	- ស.ន.ភ.ថ - រាជរដ្ឋាភិបាល - អង្គការដៃគូ - សប្បុរសជន	មេសា ២០២៦	មិថុនា ២០២៨	
ផ្នែកទី៣. ការចូលរួមរបស់ស្ត្រីនិងយុវជន ការកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ							

គ១៣-ផែនការផ្សព្វផ្សាយនិងជ្រើសរើសស្ត្រីនិងយុវជនចូលជាសមាជិកសហគមន៍នេសាទ	ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងភូមិនៃសហគមន៍នេសាទ ដែលជាស្ត្រី និងយុវជនដើម្បីចូលជាសមាជិកសហគមន៍នេសាទ ជ្រើសរើសយុវជន ស្ត្រី និងប្រជាពលរដ្ឋចូលជាសមាជិកស.ន កំពង់សាមគ្គី	-ស្ត្រីនិងយុវជនក្នុងភូមិនៃស.ន ប្រមាណ២០ភាគរយ បានយល់ដឹងពីការងារសហគមន៍នេសាទ -គណៈកម្មការនិងសមាជិកស.ន ប្រមាណបានយល់ដឹងពាក់ព័ន្ធនឹងយេនឌ័រ ឆ្លើយតបនូវតម្រូវការយេនឌ័រ -អាចយកទៅអនុវត្តន៍បាន	៦០០	- ស.ន.ភ.ថ - រាជរដ្ឋាភិបាល - អង្គការដៃគូ - សប្បុរសជន	មេសា ២០២៦	មិថុនា ២០២៨	
គ១៤-ផែនការកសាងភាពធននឹងការប្រែប្រួលអាកាសធាតុ	ប្រជុំផ្សព្វផ្សាយស្តីពី ៖ -ការរៀបចំនិងទុកដាក់សម្រាម -បទពិសោធន៍នានាទទួលបានពាក់ព័ន្ធនឹងសុខភាព អនាម័យ	-សមាជិកស.ន និងអ្នកមិនមែនជាសមជិកស.នបានយល់ដឹង និងអនុវត្តតាមប្រមាណ៥០ភាគរយ -សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការផ្សព្វផ្សាយប្រមាណ២០ភាគរយ -សម្រាមនៅក្នុងសហគមន៍មានការថយចុះ ប្រមាណ៩០ភាគ	១០ ០០០	- ស.ន.ភ.ថ - រាជរដ្ឋាភិបាល - អង្គការដៃគូ - សប្បុរសជន	មេសា ២០២៦	មិថុនា ២០២៨	
	-វគ្គបណ្តុះបណ្តាលពី Google map, Avenza maps and GField -ការគ្រប់គ្រងនិងសារៈសំខាន់នៃធនធានធម្មជាតិជាពិសេសព្រៃកោងកាង -សិទ្ធិមូលដ្ឋានលើធនធានធម្មជាតិ -វគ្គបណ្តុះបណ្តាលនៃការប្រែប្រួលអាកាសធាតុ	-គណៈកម្មការស.ន១១នាក់ យល់ដឹងពី Google map, Avenza maps and GField -គណៈកម្មការ និងសមាជិកស.ន ប្រជាពលរដ្ឋបានយល់ដឹងនិងអាចអនុវត្តន៍២០ភាគរយ -គណៈកម្មការ និងសមាជិកស.ន ប្រមាណ៥០នាក់ បានយល់ដឹង	១ ៦៥០				

		និងអាចអនុវត្តន៍បានការងារជាក់ស្តែងឆ្លើយតបនឹងការកសាងភាពស៊ាំនៃការប្រែប្រួលអាកាសធាតុ					
ផ្នែកទី៤. ការទំនាក់ទំនងនិងគៀងគរធនធាន និងថវិកា							
គ១៥-ផែនការទំនាក់ទំនង និងគៀងគរធនធាន	ផ្សព្វផ្សាយផែនការគ្រប់គ្រងស.នដល់អាជ្ញាធរសង្កាត់ ជំនាញ និងអង្គការដៃគូ	អាជ្ញាធរ ជំនាញ និងអង្គការដៃគូបានដឹងពីផែនការគ្រប់គ្រងស.ន នឹងគាំទ្រដល់ផែនការគ្រប់គ្រងប្រមាណ៩០ភាគរយ	១ ៣០០	- ស.ន.ភ.ថ - រាជរដ្ឋាភិបាល - អង្គការដៃគូ - សប្បុរសជន			
	ធ្វើសមាហរណ៍កម្មផែនការគ្រប់គ្រងសហគមន៍នេសាទចូលក្នុងផែនការអភិវឌ្ឍ និងផែនការវិនិយោគសង្កាត់	-បញ្ចូលផែនការគ្រប់គ្រងស.នចូលក្នុងផែនការអភិវឌ្ឍនិងផែនការ វិនិយោគសង្កាត់ -ទទួលបានថវិកាអនុវត្តន៍ការងារ					
	គៀងគរថវិកាដើម្បីឧបត្ថម្ភ ឬបដិភាគដល់ប្រជានេសាទដែលឈប់ឬផ្លាស់ប្តូរការប្រើឧបករណ៍នេសាទខុសច្បាប់	កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ប្រមាណ៥០ភាគរយ					
គ១៦.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ	-ប្រមូលភាគទានសមាជិកភាព -ប្រមូលភាគទានប្រចាំឆ្នាំ -ភាគទានក្រុមមុខរបររបស់ស.ន - កម្រៃអ្នកនេសាទមិនមែនជាសមាជិក និងអ្នកមកពីក្រៅ	មានថវិកាអនុវត្តន៍សកម្មភាពគ្រប់គ្រងសហគមន៍នេសាទ		គណៈកម្មការ និងសមាជិកសហគមន៍នេសាទ	មេសា ២០២៦	មិថុនា ២០២៨	
	សរសេរគម្រោងស្នើសុំពី ៖ ស្ថាប័នពាក់ព័ន្ធ (មន្ទីរជុំវិញខេត្ត) អង្គការដៃគូនានា និងសប្បុរសជន	៤០០ ៦៦៨,៨៨	- រាជរដ្ឋាភិបាល - អង្គការដៃគូនានា - សប្បុរសជន			ប៉ាន់ស្មានការរៀបចំគម្រោង ៥០០ ដុល្លារ	

គ១៧.ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ	- ប្រជុំផ្ទៃក្នុងប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ ១២លើក - រៀបចំសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីសមាជិកស.ន យុវជន និងស្ត្រីចំនួន៣លើក - ប្រជុំបូកសរុបការងារជាមួយអាជ្ញាធរជំនាញជលផល ប្រចាំឆ្នាំ៣លើក	- បានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការគ្រប់គ្រងរបស់សហគមន៍នេសាទ - ដឹងពីប្រសិទ្ធភាពនិងលទ្ធផលនៃការអនុវត្តផែនការរបស់ស.ន នៅពេលបញ្ចប់គម្រោងផែនការ	៨២០		មេសា ២០២៦	មិថុនា ២០២៨	ប្រចាំត្រីមាស និងប្រចាំឆ្នាំ

(ស.ន = សហគមន៍នេសាទ, ស.ន.ភ.ថ = សហគមន៍នេសាទកំពង់សាមគ្គី)

សកម្មភាព	កាលបរិច្ឆេទ																	
	២០២៦						២០២៦			២០២៧			២០២៨					
	មេសា	សីហា	កញ្ញា	តុលា	វិច្ឆិកា	ធ្នូ	មីនា	....	ធ្នូ	មីនា	....	ធ្នូ	មីនា	កុម្ភៈ	មីនា	មេសា	ឧសភា	មិថុនា
ផ្នែកទី១. ការអភិបាលរកិច្ចនិងការគ្រប់គ្រង																		
គ១.ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ																		
គ២.ផែនការប្រជុំប្រចាំខែនិងទិញសម្ភារការិយាល័យ																		
គ៣.ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល																		
គ៤.ផែនការប្រើប្រាស់ឧបករណ៍នេសាទ																		
គ៥.ផែនការទប់ស្កាត់បទល្មើសជលផល																		
គ៦.ផែនការកែលម្អកន្លែងនេសាទសហគមន៍																		
គ៧.ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផល																		
គ៨.ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្តាមសេះ																		
គ៩.ផែនការគ្រប់គ្រងព្រៃកោងកាង																		
ផ្នែកទី២.សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នេសាទ																		
គ១០.ផែនការបង្កើតមុខរបរសមាជិកសហគមន៍នេសាទ																		
គ១១.ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍																		
គ១២.ផែនការបង្កើតកន្លែងទេសចរណ៍ធម្មជាតិ																		
គ១៣.ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ																		
ផ្នែកទី៣.ការចូលរួមរបស់ស្ត្រី និងយុវជន ការកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ																		
គ១៤.ផែនការជ្រើសរើសស្ត្រីនិងយុវជនចូលជាសមាជិក																		
គ១៥-ផែនការកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ																		
គ១៦-ផែនការទំនាក់ទំនង និងគៀងគរធនធាន																		
គ១៧.ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ																		

លេខ.[illegible]

សូមគោរពជូន
លោកមេឃុំកូនសត្ត
«ដើម្បីជូនពិនិត្យនិងសម្រេច»
ថ្ងៃ[illegible]ខែ[illegible]ឆ្នាំ[illegible]ស័ក.ស[illegible]
[illegible]ថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ[illegible]
ប្រធានគណៈកម្មការសហគមន៍នេសាទកំពង់សាមគ្គី

[signature]

លេខ.[illegible]

សូមគោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលកំពត
«ដើម្បីជូនពិនិត្យនិងសម្រេច»
ថ្ងៃ[illegible]ខែ[illegible]ឆ្នាំ[illegible]ស័ក.ស[illegible]
[illegible]ថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ[illegible]
ជ.នាយផ្នែករដ្ឋបាលជលផលព្រែកត្នោត

[signature]

លេខ.[illegible]

សូមគោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលព្រែកត្នោត
«ដើម្បីជូនពិនិត្យនិងសម្រេច»
ថ្ងៃ[illegible]ខែ[illegible]ឆ្នាំ[illegible]ស័ក.ស[illegible]
[illegible]ថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ[illegible]
មេឃុំកូនសត្ត

[signature]

ទុត សុភ័ក្ត្រ

លេខ.[illegible]

បានឃើញនិងសូមគោរពជូន
លោកប្រធាន
មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពត
«ដើម្បីជូនពិនិត្យនិងសម្រេច»
ថ្ងៃ[illegible]ខែ[illegible]ឆ្នាំ[illegible]ស័ក.ស[illegible]
[illegible]ថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ[illegible]
នាយខណ្ឌរដ្ឋបាលជលផលកំពត

[signature]

ស_សុវិន

លេខ.[illegible]

បានឃើញនិងសូមគោរពជូន
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
«ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ»
ថ្ងៃ[illegible]ខែ[illegible]ឆ្នាំ[illegible]ស័ក.ស[illegible]
[illegible]ថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ[illegible]
ប្រធាន
មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពត

[signature]

ចាន់ រិទ្ធិ

លេខ.[illegible]ជផ

បានឃើញនិងឯកភាព
ថ្ងៃ[illegible]ខែ[illegible]ឆ្នាំ[illegible]ស័ក.ស[illegible]
រាជធានីភ្នំពេញ ថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ[illegible]
ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលជល

[signature]

ញ៉ ស្រស